# សុន្ទរកថាស្វាគមន៍
# របស់ ឯកឧត្តមបណ្ឌិត ខួន ញ៉ិល អនុប្រធានទី២រដ្ឋសភា
# និងជាប្រធានគណៈកម្មការរៀបចំមហាសន្និបាត
# ថ្លែងក្នុងពិធីបើកមហាសន្និបាតលើកទី៨នៃសភាតំបន់អាស៊ី
# "ការជម្រុញសន្តិភាព ការផ្សះផ្សា និងការសន្ទនាក្នុងតំបន់អាស៊ី"
# រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥

---

*សូមគោរព:*

*-សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា*

*និងជាប្រធានសភាតំបន់អាស៊ី (អេភីអេ)*

*- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា*

*- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*

*នៃព្រះរាជាណាចក្រកម្ពុជា*

*- ឯកឧត្តម មីយ៉ាន រ៉ាហ្សា រ៉ាបានី ប្រធានព្រឹទ្ធសភាប៉ាគីស្ថាន និងជាប្រធានអេភីអេ*

*បច្ចុប្បន្ន*

*-ឯកឧត្តមបណ្ឌិត ម៉ាស៊ូឌ អ៊ីស្លាមី អគ្គលេខាធិការ អេភីអេ ស្តីទី*

*-ឯកឧត្តម លោកជំទាវ ប្រធាននិងសមាជិកគណៈប្រតិភូសមាជិកសភាអេភីអេ និង*

*គណៈប្រតិភូ ប្រទេសសង្កេតការណ៍ទាំងអស់ជាទីមេត្រី!*

*-ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*

*អង្គការជាតិ និងអន្តរជាតិ និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី*

១-ជាបឋម ក្នុងនាមគណៈកម្មការរៀបចំមហាសន្និបាតលើកទី ៨ សភាតំបន់អាស៊ី (អេ-ភី-អេ) និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងដោយស្មោះចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ ប្រធានគណៈប្រតិភូ សមាជិក សមាជិកាគណៈប្រតិភូសភាសមាជិកអេភីអេ ប្រតិភូប្រទេសសង្កេតការណ៍ អង្គការជាតិ និងអន្តរជាតិទាំងអស់ ជាពិសេស វត្តមានដ៏ឧត្តុងឧត្តមរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

២- ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលេខាធិការដ្ឋានអេភីអេ ជាពិសេស ឯកឧត្តមអគ្គលេខាធិការអេ-ភី-អេ ដែលបានខិតខំប្រឹងប្រែងនិងលះបង់អស់ពីកំលាំងកាយចិត្តក្នុងការជួយជ្រោមជ្រែង និងរៀបចំឯកសារពាក់ព័ន្ធសំខាន់របស់មហាសន្និបាត ក្នុងនោះ សេចក្តីព្រាងសេចក្តីសម្រេចដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំគណៈកម្មការនានារបស់អេភីអេ ដើម្បីដាក់ជូនអង្គមហាសន្និបាតលើកទី៨ ពិនិត្យ និងអនុម័ត។ ទន្ទឹមនឹងនេះដែរ ក្នុងនាមរដ្ឋសភាកម្ពុជា ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះរដ្ឋសភានៃសាធារណរដ្ឋអ៊ិស្លាមអ៊ីរ៉ង់ ដែលជានិច្ចកាលតែងតែជួយឧបត្ថម្ភ និងគាំទ្រទាំងផ្នែកស្មារតី និងសំភារៈដល់កិច្ចដំណើរការងាររបស់លេខាធិការដ្ឋានអេភីអេ ជាពិសេស ចំពោះការស្ម័គ្រចិត្តទទួលរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី ១ និងកិច្ចប្រជុំគណៈកម្មាធិការសង្គមនិងវប្បធម៌កាលពីវិច្ឆិកា ឆ្នាំ២០១៥ ប្រកបដោយជោគជ័យ។

សម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី ជាទីមេត្រី!

៣-សភាកម្ពុជា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូល មានកិត្តិយស និងក្តីសោមនស្សរីករាយ ប្រកបដោយមោទនភាពបំផុតដែលត្រូវបានសភាសមាជិកអេភីអេផ្តល់សេចក្តីទុកចិត្ត និងបានបោះឆ្នោតគាំទ្រដល់សភាកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះទទួលរៀបចំ និងធ្វើជាប្រធានមហាសន្និបាតលើកទី ៨ អេភីអេ នាឆ្នាំ២០១៥ និងលើកទី ៩ នាឆ្នាំ ២០១៦ ។ នេះឆ្លុះបញ្ចាំងឲ្យឃើញថា កម្ពុជាពិតជាមានសមត្ថភាព និងលទ្ធភាពក្នុងបរិយាកាសប្រកបដោយសន្តិភាព ស្ថេរភាពនយោបាយ និងសុវត្ថិភាពពេញលេញ ក្នុងការទទួលរៀបចំព្រឹត្តិការណ៍ជួបជុំជាប្រវត្តិសាស្ត្រនៃតំណាងប្រជាពលរដ្ឋតំបន់អាស៊ីយើងនេះ។

៤-មូលបទនៃមហាសន្និបាតអេ-ភី-អេលើកទី ៨ ស្តីពី **"ការលើកកម្ពស់សន្តិភាព ការផ្សះផ្សា និងកិច្ចសន្ទនាក្នុងតំបន់អាស៊ី"** ជាប្រធានបទមួយដ៏មានសារសំខាន់ និងសមស្របបំផុតទៅនឹងបរិបទតំបន់ និងពិភពលោកបច្ចុប្បន្ន ដែលកំពុងជួបប្រទះនូវការប្រឈម និងវិបត្តិធ្ងន់ធ្ងរ ដែលក្នុងនោះរួមមាន អំពើភេរវកម្ម អំពើហិង្សាជ្រុលនិយមដែលបង្កឲ្យមានអស្ថេរភាពនយោបាយ និងមហន្តរាយដល់សង្គម ជាពិសេសអំពើភេរវកម្មដែលបានកើតឡើងថ្មីៗនៅក្នុងទីក្រុងប៉ារីសដោយបានវាយប្រហារ និងសម្លាប់ប្រជាពលរដ្ឋស្លូតត្រង់អស់រាប់រយនាក់។ វាជាបញ្ហាប្រឈមដែលយើងទាំងអស់គ្នាត្រូវរួមគ្នាដោះស្រាយ ដើម្បីឲ្យប្រជាពលរដ្ឋក្នុងតំបន់អាស៊ី នេះបានរស់នៅក្នុងសុខសន្តិភាព និងវិបុលភាព និងរួចចាកផុតពីការភ័យខ្លាច។ម្យ៉ាងវិញទៀត មូលបទនៃមហាសន្និបាតលើកទី ៨ នេះក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងមូលបទនៃមហាសន្និបាតលើកទី៧ ស្តីពី"កិច្ចស្វះស្វែងរួមគ្នាដើម្បីកសាងសភាអាស៊ីក្នុងសតវត្សរ៍ អាស៊ី"ដែលបានរៀបចំនៅទីក្រុងឡាហ័រ ប្រទេសប៉ាហ្គីស្ថាន កាលពីឆ្នាំ

២០១៤ កន្លងទៅ និងខ្លឹមសារនៃប្រធានបទកិច្ចប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍ របស់ អេភីអេ ផងដែរ។

*សម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី ជាទីមេត្រី!*

៥- សន្តិភាព ស្ថេរភាពនយោបាយ ការផ្សះផ្សា និងកិច្ចសន្ទនាដោយសន្តិវិធី ជាកត្តាសំខាន់ចាំបាច់ និងជាបុរេលក្ខខណ្ឌក្នុងការកសាង និងអភិវឌ្ឍប្រទេស និង សង្គមជាតិមួយឲ្យមានភាពរីកចម្រើន ជឿនលឿន ប្រកបដោយនិរន្តរភាព និង ភាពសុខដុមរម្យនា។ កម្ពុជាធ្លាប់បានឆ្លងកាត់ និងមានបទពិសោធន៍យ៉ាងល្វីង ជូរចត់ នៃសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ ការបែកបាក់ផ្ទៃក្នុងជាតិ និងអស្ថេរភាពនយោបាយ អស់ជាងបីទសវត្សរ៍ ជាពិសេសរបបប្រល័យពូជសាសន៍ ដែលបាន ធ្វើឲ្យសង្គម កម្ពុជាធ្លាក់ដល់កម្រិតសូន្យដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។

៦-សន្តិភាព ស្ថេរភាពនយោបាយ ការផ្សះផ្សាជាតិ និងកិច្ចសន្ទនាប្រកបដោយ សន្តិវិធី ជាកត្តាគន្លឹះ និងចាំបាច់បំផុតទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងសកល លោក ក្នុងការកសាង ប្រទេសមួយ តំបន់មួយ និងពិភពលោកមួយឲ្យមានភាព រីកចម្រើន និងសុខដុមរមនា។ក្នុងន័យនេះ យើងត្រូវបន្តជម្រុញ និងពង្រឹងសន្តិភាព និង កិច្ចសន្ទនាដោយសន្តិវិធីនិងគោរពតាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ ក្នុងការស្វែងរកដំណោះស្រាយសមស្របណាមួយដើម្បីបញ្ចប់បញ្ហាប្រឈមនានា នៅក្នុងតំបន់និងពិភពលោក ពីព្រោះសន្តិភាព និងស្ថេរភាពនយោបាយក្នុងតំបន់ ជាគន្លឹះមួយដែលមិនអាចខ្វះបានក្នុងកិច្ចអភិវឌ្ឍនិងវិបុលភាពសង្គម។

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!*

៧-ក្រៅពីកិច្ចពិភាក្សាលើមូលបទខាងលើ យើងក៏នឹងមានកិច្ចពិភាក្សាអំពីបញ្ហាសំខាន់រួមផ្សេងៗនៅកិច្ចប្រជុំគណៈកម្មការធិការអចិន្ត្រៃយ៍នានា ដែលនឹងផ្តោតលើតួនាទីសំខាន់របស់សមាជិកសភាក្នុងការប្រឆាំងអំពើពុករលួយ ការតាក់តែងច្បាប់សម្រាប់ប្រឆាំងការជួញដូរសម្បត្តិវប្បធម៌ក្នុងតំបន់អាស៊ី កិច្ចការពារនិងការលើកស្ទួយសិទ្ធិពលករទេសន្តប្រវេសន៍ ការលើកកម្ពស់សុខុមាលភាព ការជម្រុញអន្តរជំនឿ និងភាពសុខដុមរមនាក្នុងចំណោមពហុសាសនា និងការប្រយុទ្ធប្រឆាំង នឹងការជួញដូរគ្រឿងញៀនខុសច្បាប់ ជាដើមៗ

៨- ខ្ញុំមានជំនឿ និងសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវកិត្តិយសទាំងអស់នឹងចូលរួមយ៉ាងសកម្ម ក្នុងការពិភាក្សា ផ្លាស់ប្តូរទស្សនៈយោបល់គ្នាទៅវិញទៅមកយ៉ាងផុលផុស ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ គោរពគ្នាទៅវិញទៅមក និងក្នុងស្មារតីមិត្តភាព និងកិច្ចសហប្រតិបត្តិការ ដែលរួមចំណែក និងវិភាគទានយ៉ាងធំធេងចំពោះជោគជ័យនៃមហាសន្និបាតលើកទី ៨ នេះៗ ក្នុងនាមជាម្ចាស់ផ្ទះរៀបចំមហាសន្និបាត និងជាប្រធានគណៈកម្មការរៀបចំមហាសន្និបាត យើងខ្ញុំនឹងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីបម្រើឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដើម្បីធ្វើទទួលបាននូវផាសុកភាព សុវត្ថិភាព ក្នុងអំឡុងពេលស្នាក់ នៅព្រះរាជាណាចក្រកម្ពុជាៗ ក្នុងន័យនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់មេត្តា ជម្រាបមកយើងខ្ញុំប្រសិនបើមានសេចក្តីតម្រូវការអ្វីមួយៗ យើងខ្ញុំនឹងខិតខំឆ្លើយតបជូនឲ្យទាន់ពេលវេលាតាមតែអាចធ្វើទៅបាន ដើម្បីធ្វើយ៉ាងណាឲ្យដំណើរការនៃមហាសន្និបាតនេះទទួលបានជោគជ័យ និងលទ្ធផលផ្លែផ្កាតាមការរំពឹងទុកៗ ជាមួយគ្នានេះដែរយើងខ្ញុំក៏សូមអភ័យទោសទុកជាមុន

ប្រសិនបើមានប្រការខកខានណាមួយ ដែលមិនបានបំពេញ ដែលស្ថិតនៅក្រៅពីបំណងរបស់យើងខ្ញុំ ។

៩-មុននឹងបញ្ចប់តាងនាមឲ្យគណៈកម្មការរៀបចំមហាសន្និបាត ខ្ញុំសូមថ្លែងអំណរគុណជាថ្មីចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាចូលរួមមហាសន្និបាតលើកទី ៨ ដ៏មានសារសំខាន់នេះ និងសូមគោរពជូនពរសូមទទួលបាននូវសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។

១០-ជាទីបញ្ចប់តាងនាមគណៈកម្មការរៀបចំមហាសន្និបាតអេភីអេលើកទី ៨ ខ្ញុំសូមអំពាវនាវ និងលើកទឹកចិត្តដល់សភាសមាជិកអេ-ភី-អេប្រទេសសង្កេតការណ៍ និងដៃគូពាក់ព័ន្ធទាំងអស់បន្ត និងលើកកម្ពស់ការគាំទ្រ និងចូលរួមកាន់តែសកម្ម ដើម្បីសម្រេចបាននូវចក្ខុវិស័យរួមរបស់យើងក្នុងការប្រែក្លាយអេភីអេ ទៅជាសភាអាស៊ីនាពេលអនាគត ដែលជាស្ថាប័ននីតិបញ្ញត្តិតំបន់មួយប្រកបដោយ សមភាព ប្រសិទ្ធភាពនិងគណនេយ្យភាព និងតំណាងឲ្យប្រជាពលរដ្ឋនៅទូទាំងអាស៊ីឲ្យបានរស់នៅក្នុងសុខសន្តិភាព ស្ថេរភាព និងភាពសុខដុមរមនា ប្រកបដោយចីរភាព។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!

**Welcome Remarks**

**Honorable Dr. NGUON Nhel, Second Vice-President of the National Assembly of the Kingdom of Cambodia and Chairman of the Organizing Committee of 8th APA Plenary Session**

**At the Inaugural Ceremony of the 8th APA Plenary Session**

**Under the theme:**

**"Promoting Peace, Reconciliation and Dialogue in Asia"**

**Date: 9th December 2015**

**Venue: Sokha Phnom Penh Hotel and Residence**

My respects to:

- Honorable Samdech Akka Moha Ponhea Chakrei Heng Samrin, President of the National Assembly of the Kingdom of Cambodia,
- Honorable Samdech Vibol Sena Pheakdei SAY Chhum, President of the Senate of the Kingdom of Cambodia;
- Honorable Samdech Akka Moha Sena Padei Techo HUN Sen, Prime Minister of the Kingdom of Cambodia;
- Honorable MIAN Raza Rabbani, President of the Pakistan Senate and Current APA President;
- Honorable Heads and Members of Delegations of the APA Member Parliaments, Honorable Delegations of Observer Countries and Partner Organizations of APA;
- Your Excellency Dr. MASOUD Islami, Acting Secretary-General of APA;
- Your Excellencies Ambassadors to the Kingdom of Cambodia
- Excellencies, National and International Distinguished Guests, Ladies and Gentlemen;

1. First of all, on behalf of the Organizing Committee of 8th Plenary Session of Asian Parliamentary Assembly (APA), I wish to express my sincere and deep thanks to all Honorable Heads and Member Delegates of APA Member Parliaments, Delegates of Observer Parliaments and all national and international distinguished participants, in particular Honorable Samdech Akka Moha Sena Padei Techo Hun Sen, Prime Minister of the Royal Government of Cambodia and Honorable Samdech Vibol Sena Pharkdei Say Chhum, President of the Senate, for their valuable presence at the 8th Plenary Session of APA.

2. In addition, I wish to thank the APA Secretariat, especially His Excellency the Acting Secretary General of APA for his great efforts and commitment to support and prepare all necessary documents, including draft resolutions of the APA Standing Committees to be submitted to the 8th Plenary Session for consideration and adoption. At the same time, on behalf of the Cambodian National Assembly, I wish to deeply thank the Consultative Assembly of the Islamic Republic of Iran for its valuable supports both technical and financial supports for the work and functioning of APA, in particular the successful voluntary host of the First Executive Council meeting and the meeting of the Standing Committee on Social and Cultural Affairs in early November.

3. The Cambodian Parliament, the Royal Government and the people of Cambodia have the great honor and pleasure with great pride to be given the trust and support to be the host of the 8th and 9th Plenary Session of APA in 2015 and 2016. This really shows that Cambodia has full capacity and favorable conditions of full peace, political stability and safety to hold a historical gathering of representatives of the people in our region.

4. The theme of the 8th APA Plenary Session on "Promoting Peace, Reconciliation and Dialogue in Asia" is a very important and relevant topic to the current regional and global context which is facing a lot of challenges and serious crises, such as terrorism and extreme violence that causes political instability and chaos to society, especially the attacks in Paris that killed more than hundreds of innocent people. These are the challenges we all need to resolve together to ensure our people in Asia live in peace, prosperity and without fear. Moreover, this theme is very connected to the contents of the various Standing Committees and the last year's 7th APA Plenary Session on "Quest for Asian Parliament in Asian Century" which was held in Lahore, Pakistan.

***Samdech, Honorable Delegates,***
***Excellencies, Ladies and Gentlemen,***

5. "Peace, Political Stability, Reconciliation" are key factors and pre-conditions for building and developing a society and country with prosperity, sustainable development and harmony. Cambodia experienced bitter civil war, internal division and political instability for more than three decades, in particular genocidal Pol Pot Regime that killed millions of its own citizens and brought Cambodian society to zero.

6. Peace, political stability, national reconciliation and peaceful dialogue are key and necessary for nations, regions and the whole world to build and develop to obtain prosperity and harmony. In this regard, we all need to continue to promote and strengthen peace and dialogue and respect the principles of democracy and the rule of laws in seeking appropriate resolutions. Peace and political stability in the region is an indispensable factor to sustainable development and social welfare.

***Samdech, Honorable Delegates,***

***Excellencies, Ladies and Gentlemen,***

7. Apart from having general discussions on the theme, we also have a debate on a number of common issues of our region at various Standing and Ad-Hoc Committees over key roles of Parliaments in combating corruption, common legislation on Combating the smuggling of cultural objects in Asia, protecting and promoting the rights of migrants, promoting welfare, promoting inter-faiths dialogue and harmony between religions and the fight against illegal drug-smuggling.

8. I strongly believe that with your active participation in the discussions and exchanges of ideas and perspectives with your esteem responsibility and mutual understanding, in the spirit of solidarity and cooperation, you will offer great contributions to the success of this 8th Plenary Session.

9. As Host of the Plenary Session and Chairman of the Organizing Committee, we do our best to server all Honorable Delegates and all distinguished participants to enjoy comfort, safety and pleasure during your stay in the Kingdom of Cambodia. Please do not hesitate to let us know if you have any kind of request. We will do our best to accommodate your proposal and do as much as we can to ensure the progress and functioning of this Plenary Session to achieve success and fruitful result. At the same time, we sincerely apologize for any inconvenience you may encounter.

10. Before I conclude, on behalf of the Organizing Committee, I would like to express my sincere thanks to Samdech, Honorable Delegates, Excellencies,

and all distinguished participants for taking their valuable time to attend the 8th Plenary Session and I offer the best wishes and success to all of you.

11. To conclude my remarks, I appeal and encourage all APA member parliaments, observer parliaments and concerning partner organizations to continue and enhance their support and active participations to achieve our common vision in transforming the Asian Parliamentary Assembly into the Asian Parliament in the future, as an effective, accountable and equitable regional legislature that represents all the peoples of Asia to live in peace, stability and harmony and with sustainable development.

Thank you for your kind attention.